ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៧នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ :

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០១លើក

-អនុញ្ញាឲ្យឯកឧត្តម Bounnhang Vorachith ប្រធានាធបតី និងគណៈប្រតិភូ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចូលជួបសម្តែងការគួរសម និងសវនាការ

-អនុញ្ញាតឲ្យ **ឯកឧត្តម** IWAI Shigeki សមាជិកព្រឹទ្ធសភា និងគណៈប្រតិភូ នៃព្រឹទ្ធសភាជប៉ុន ចូលជួបសម្តែងការគួរសម និងសវនាការ

-អញ្ជើញជាអធិបតីក្នុងពិធីសូត្រមន្តឡើងអាគារខុទ្ទកាល័យថ្មី របស់ថ្នាក់ដឹកនាំព្រឹទ្ធសភា

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យមាឃបូជា នៅបរិវេណព្រះមហាសក្យមុនីចេតីយភ្នំព្រះរាជទ្រព្យ ស្រុកពញាឮ ខេត្តកណ្តាល

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបំពាក់គ្រឿងឥស្សរិយយស និងមេដាយការងារជូនក្រុមប្រឹក្សាសង្កាត់ នៅខេត្តព្រះសីហនុ

-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជន៍ ជូនឯកឧត្តម Bounnhang Vorachith ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរ សង្កាត់ ភូមិ ប្រជាពលរដ្ឋ នៅសង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ និងសាកសួរសុខទុក្ខលោកគ្រូ អ្នកគ្រូព្រមទាំងក្មួយៗគរុសិស្សកម្មសិក្សានៅសាលាមត្តេយ្យវត្តកោះ ខណ្ឌដូនពេញ

-អញ្ជើញជួបសំណេះសំណាល និងទទួលទានអាហារថ្ងៃត្រង់ជាមួយបងប្អូនប្រជាពលរដ្ឋមកពីភូមិត្រពាំងពោធិ៍ ភូមិត្រពាំងក្រឡឹង ភូមិព្រៃក្តួច និងភូមិអង្គតាឯក នៃឃុំភ្នំតូច ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ និងសំណេះសំណាលជាមួយអាជ្ញាធរសង្កាត់ ភូមិ ព្រមទាំងបានឧបត្ថម្ភម៉ាស៊ីនហ្វូតូកូពីចំនួន០១គ្រឿង នៅសង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ

-អញ្ជើញចូលថ្វាយបង្គំ និងជម្រាបសួរសុខទុក្ខ ព្រះគ្រូចៅអធិការវត្ត ព្រះសង្ឃ លោកតាអាចារ្យ គណៈកម្មការវត្ត និងលោកយាយជី នៅវត្តជម្មត្រ័យ នៅភូមិជម្មត្រ័យ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល

-អញ្ជើញចូលរួមរំលែកទុក្ខក្រុមគ្រួសារ **លោក ម៉ា សេរី** អ្នកយកព័ត៌មាន និងជាពិធីករនាទីកីឡានៃស្ថានីយ៍បណ្តាញទូរទស្សន៍ CTN CNC MYTV នៅភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៨ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៦ច្បាប់ ។

**១.២.ឯកឧត្តម ង៉ែ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមក្នុងពិធីសូត្រមន្តប្រោះព្រំអាគារថ្មីរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ដើម្បីសុំសេចក្តីសុខ សេចក្តីចម្រុងចម្រើន

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ និងជ្រាបជាព័ត៌មានចំនួន៣៩ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក

-អញ្ជើញជាអធិបតីថ្ងៃសុន្ទរកថាបើកសិក្ខាសាលាថ្នាក់តំបន់ស្តីពី កំណែទម្រង់វិស័យអប់រំនៅអាស៊ាន

-អនុញ្ញាតឲ្យគណៈប្រតិភូក្រុមយុវជនកម្ពុជាប្រចាំប្រទេសបារាំង ដឹកនាំដោយលោក **សាត វិច្ឆិកា** ប្រធានក្រុមយុវជនកម្ពុជាប្រចាំប្រទេសបារាំង ចូលជួបសម្តែងការគួរសម

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះទៅពិនិត្យ និងព្យាបាលជម្ងឺដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋ នៅឃុំបារគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

-អញ្ជើញចូលរួមក្នុងពិធីបុណ្យខួបគម្រប់១០០ថ្ងៃ ឯកឧត្តម **ទិត រាម** នៅគេហដ្ឋាន បុណ្យ ខេត្តកំពង់ចាម

-អញ្ជើញនាំយកទេយ្យទានទៅប្រគេនព្រះសង្ឃគង់នៅវត្តប្រាំបីមុំ ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ

-អញ្ជើញជាអធិបតីក្នុងពិធីជប់លៀងជូនក្រុមគ្រូពេទ្យស្ម័គ្រចិត្ត មកពីប្រទេសបារាំង នៅភោជនីយដ្ឋាន Jasmine និងភោជនីយដ្ឋាននាគក្រហម ចំនួន០២លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីលៀងសាយភោជន៍ ជូនគណៈប្រតិភូនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត ឡាវ នៅសណ្ឋាគារ Sofitel Phnom Penh

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១២៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១២១ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក:**

១.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី គណបក្សនយោបាយ ។

**៣.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែកុម្ភៈនេះ សមាជិក-សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោមៈ

**៣.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្តីស្នើច្បាប់ចំនួន០១ ។

**៣.២. មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-អញ្ជើញចុះបំពេញបេសកកម្មសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ ការផ្សព្វផ្សាយព័ត៌មាន នៅខេត្តកណ្តាល ស្វាយរៀង ព្រៃវែង និងខេត្តត្បូងឃ្មុំ

-អញ្ជើញចុះទៅឈ្វេងយល់អំពី ការអនុវត្តគោលនយោបាយវិមជ្ឈការនៅថ្នាក់ក្រោមជាតិ និងការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ នៅស្រុកកៀនស្វាយ និងសាលាខេត្តកណ្តាល

-អញ្ជើញចុះបំពេញបេសកកម្មសិក្សាឈ្វេងយល់អំពីការអនុវត្តសិទ្ធិមនុស្ស និងការដោះស្រាយពាក្យបណ្ដឹងរបស់ថ្នាក់ក្រោមជាតិ នៅខេត្តពោធិសាត់ និងខេត្តប៉ៃលិន

-អញ្ជើញចុះទំនាក់ទំនងការងារជាមួយអាជ្ញាធរខេត្តព្រះសីហនុ ដើម្បីត្រៀមលក្ខណៈរៀបចំពិធីបំពាក់គ្រឿងឥស្សរិយយសជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ខេត្តព្រះសីហនុ។

**៤.៣. មុខងារតំណាង**

-បានទទួលពាក្យបណ្ដឹងចំនួន០៤ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០២ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្ដឹងពីស្ថាប័នមានសមត្ថកិច្ចចំនួន០១ករណី និងទទួលពាក្យបណ្ដឹងជូនជ្រាបចំនួន០៣ករណី

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បើកកិច្ចប្រជុំ ពិនិត្យ និងសម្រេចលើគម្រោងចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរស្រុក ឃុំ ដើម្បីឈ្វេងយល់ និងរិះរកដំណោះស្រាយការប្រឈមរបស់ក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម និងស្រុកតំបែរ ខេត្តត្បូងឃ្មុំ

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បើកកិច្ចប្រជុំដើម្បីពិភាក្សាពីការចុះត្រួតពិនិត្យ និងតាមដានលទ្ធផលនៃការធ្វើវេទិកាភូមិភាគកន្លងមកនៅខេត្តបន្ទាយមានជ័យ

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ បើកកិច្ចប្រជុំដើម្បីត្រៀមរៀបចំពិធីបំពាក់គ្រឿងឥស្សរិយយសជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ខេត្តព្រះសីហនុ និងត្រៀមរៀបចំសិក្ខាសាលាថ្នាក់តំបន់អាស៊ាន

-ក្រុមសមាជិកាព្រឹទ្ធសភា បើកកិច្ចប្រជុំដើម្បីពិភាក្សាអំពីសកម្មភាពការងារក្រុមដែលត្រូវអនុវត្តនាពេលខាងមុខ

-អញ្ជើញចូលរួមកិច្ចពិគ្រោះយោបល់ជាមួយសមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ មកពីខេត្តស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរីស្ដីពី ការជម្រុញស្ត្រីចូលរួមជ្រើសរើសអ្នកដឹកនាំឃុំ-សង្កាត់

-អញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមការងារ ចុះផ្សព្វផ្សាយអំពីការរីកចម្រើនរបស់នារីកម្ពុជា នៅទីស្នាក់ការកណ្ដាលសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍

-អញ្ជើញចូលរួមកម្មវិធីសំណេះសំណាល ជាមួយនិស្សិតសាកលវិទ្យាល័យខេមរៈក្រោមប្រធានបទស្ដីពី ការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម

-អញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីផែនការអនុវត្តសេចក្តីសម្រេចរបស់ព្រឹទ្ធសភាស្តីពីការបង្កើតក្រុមការងាររៀបចំសេចក្តីព្រាងដើមទូវឯកសារក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា

-អញ្ជើញចូលរួមប្រជុំក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាជាមួយព្រឹទ្ធសភាបារាំង ដើម្បីពិភាក្សាអំពីការត្រៀមលក្ខណៈរៀបចំសិក្ខាសាលា និងការសម្តែងសិល្បៈ ដើម្បីអបអរសាទរទិវាភាសាបារាំង

-អញ្ជើញចូលរួមអបអរសាទរសិក្ខាសាលាតំបន់ស្តីពី កំណែទម្រង់វិស័យអប់រំ និងការផ្សព្វផ្សាយសេចក្តីព្រាងសៀវភៅផែនទីភូមិសាស្ត្រនយោបាយកម្ពុជា

-អញ្ជើញចូលរួមសិក្ខាសាលាតំបន់ស្តីពី កំណែទម្រង់ការអប់រំនៅតំបន់អាស៊ាន

-អញ្ជើញចូលរួមធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភាជូនដល់មន្ត្រីមកពីសភាឡាវ មីយ៉ាន់ម៉ា ម៉ាឡេស៊ី ហ្វីលីពីន និងថៃ ចំនួន១៧នាក់

-អញ្ជើញចូលរួមក្នុងពិធីប្រកាសគណៈកម្មការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ និងក្រុមចលនាស្ត្រីខេត្តព្រៃវែង

-អញ្ជើញចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ របស់សមាគមនារីអាស៊ានកម្ពុជា

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន២៥៤លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានាតាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្សការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៥១លើក ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-លោកជំទាវ **ទី បូរ៉ាស៊ី** អញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់សភានិយាយភាសាបារាំង(APF) នៅប្រទេសប៊ែលហ្ស៊ិក

-ឯកឧត្តម **ជា ជេដ្ឋ** អញ្ជើញចូលរួមប្រជុំជាមួយលោកស្រី Lange Anne-Marie Gabrielle M. ប្រតិភូស្ថានទូតសហគមន៍បែលហ្ស៊ិកប្រចាំនៅប្រទេសវៀតណាម ដើម្បីពិនិត្យ និងឆ្លងសេចក្តីព្រាងកម្មវិធីដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់នៃ PF WB នៅកម្ពុជា

-ឯកឧត្តម **ម៉ាន់ ឈឿន** អញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម NUTTAVUDH PHOTISARO ឯកអគ្គរាជទូតថៃប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងជួបពិភាក្សាការងារជាមួយតំណាងអង្គការ UNESCO ប្រចាំនៅរាជធានីភ្នំពេញ ។/

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៧

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ